# ការសំភាសន៍របស់ ប្រាក់ ចាន់ធី

**កៈ អ្នកដែរសំភាសន៍គេ ជាង ស៊ីអ៊ាវ ខៈ អ្នកដែរអោយគេសំភាសន៍ ប្រាក់ ចាន់ធី**

កៈ ចឹងជាដំបូងខ្ញុំអរគុណច្រើនបងដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់បង ហើយការសំភាសន៍មួយនេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថា BYU ហាសបង ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរ ដើម្បីអោយកូនចៅជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិឪពុកម្ដាយនឹងដូនតាចឹងហាសបង បាទចឹងពេលខ្ញុំសំភាសន៍បងហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistoryproject.byu.edu ចឹងហាសបង ចឹងសំរាប់បង តើបងយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរទេបង?

ខៈ ចាអ្វីដែរធ្វើទៅវាសមស្របធ្វើ តែបើធ្វើទៅវាខុសច្បាប់មានបញ្ហាទាក់ទិនទៅនឹងបញ្ហាអីផ្សេងៗខ្ញុំពិបាកក្នុងការអោយចាក់ផ្សាយ។

កៈ បាទបង និយាយរួមយើងអត់ចាក់ផ្សាយគេគ្រាន់តែ keep ទុកអោយយើងទេបង គេរក្សាទុកអោយយើងទេ ហើយនៅពេលដែរគេរក្សាទុកអោយយើងហើយមួយទៀតនឹងគេនឹងយកមកអោយបងវិញទេបងគេនឹងមិនបញ្ចេញជាសាធារណៈទេបង ចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍បងខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ាវ ហើយការសំភាសន៍មួយនេះត្រូវបានធ្វើនៅថ្ងៃទី២៦ ខែ១ ឆ្នាំ២០១៨ ហើយធ្វើនៅភូមិ៤ សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញហាសបង ចុះសំរាប់បងមានឈ្មោះពេញនឹង ឈ្មោះអីគេដែរបង?

ខៈ ឈ្មោះ ប្រាក់ ចាន់ធី។

កៈ ឈ្មោះ ប្រាក់ ចាន់ធី ចុះមានឈ្មោះហៅក្រៅទេបង?

ខៈ ឈ្មោះ ចាន់ ធី។

កៈ ចុះកាលពីក្មេងមានធ្លាប់មាននរណាគេហៅឈ្មោះបងអីផ្សេងទេ?

ខ៖ អត់មានទេ។

ក៖ ហៅតែមួយនឹងទេណបង?

ខ៖ ចាមានតែមួយ។

ក៖ ចុះបងសព្វថ្ងៃនឹងបងអាយុប៉ុន្មានដែរបង?

ខ៖ ខ្ញុំអាយុ៨២ឆ្នាំ។

ក៖ ចុះបងមានដឹងថាបងកើតនៅថ្ងៃខែឆ្នាំណាដែរទេបង?

ខ៖ ខែបារាំង រឺមួយក៏ខែខ្មែរ?

ក៖ ខែបារាំងហាសបង?

ខ៖ ខែបារាំងថ្ងៃទី៣ ខែ២ ឆ្នាំ១៩៧៦។

ក៖ ចុះបងឆ្នាំច័ន្ទគតិបងឆ្នាំអីគេដែរបងឆ្នាំ ជូត ឆ្លូវ ខាល ថោះហាសបង?

ខ៖ ខ្ញុំឆ្នាំរោង ។

ក៖ អូឆ្នាំរោងហោស ចុះបងកើតនៅភូមិអី ឃុំអី ស្រុកអី ខេត្តអីដែរបង?

ខ៖ ភូមិត្រយ៉ូង ស្រុកបារាយណ៍ ខេត្តកំពង់ធំ។

ក៖ ចុះឃុំអីទៅបង ភូមិត្រយ៉ូង ឃុំអីគេដែរបង?

ខ៖ ឃុំពីរនឹងពិបាកអាណាសារាយណ៍ អាណាបារាយណ៍ទេពិបាកចាំហាស។

ក៖ បាទបងអត់អីទេបង ចុះបងសព្វថ្ងៃនឹងបងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរបង?

ខ៖ ខ្ញុំមានបងប្អូនខចំនួន៦នាក់ មានប្រុស៣នាក់ នឹងស្រី៣នាក់ខ្ញុំជាកូនទៅ២។

ក៖ អូបងជាកូនទី២ហោសបង?

ខ៖ ចាទី២។

កៈ ចុះបងអាចប្រាប់ឈ្មោះបងប្អូនរបស់បងបានទេ?

ខៈ ចាបងទី១ឈ្មោះ ប្រាក់ ចាន់ថៃ, ខ្ញុំទី២ឈ្មោះ ប្រាក់ ចាន់ធី, ទី៣មានឈ្មោះប្រាក់ ប៊ុនហ៊ាន, ទី៤ប្រាក់ ប៊ុនស្រ៊ុន , ទី៥ឈ្មោះ ប្រាក់ រចនា។

កៈ ចុះទី៦ពៅគេវិញ?

ខៈ ឈ្មោះ ប្រាក់ ចាន់ដា។

កៈ នឹងពៅគេប្រាក់ ចាន់ដា។

ខៈ ចាពៅគេកូនប្រុស។

កៈ អូប្អូនប្រុសហោសបង?

ខៈ ចាពៅប្រុស បងស្រី

កៈ ចុះបងមានធ្លាប់ធ្វើអីកាលពីបងនៅក្មេងៗតូចនៅជាមួយគ្នាហាសបង?

ខៈ ភាគច្រើនដូចថាខ្ញុំរស់នៅរុះរង់គ្រួសារមួយមិនមែនជាអ្នកខ្សត់ខ្សោយប៉ុន្មានទេចឹងខ្ញុំ គ្រាន់តែទៅរៀនហើយត្រលប់មកវិញគ្រាន់តែជួយមើលពួកគាត់តែប៉ុណ្ណឹងអែង។

កៈ ចុះបងមានធ្លាប់លេងឡឹកបាយឡ រឺលេងហ្គេមដូចថាលេងខ្វង លេងមឹកលេងអីជាមួយគ្នាទេបង?

ខៈ ខ្ញុំមិនសូវបានលេងអីជាមួយប្អូនទេពីព្រោះតែខ្ញុំអាយុច្រើនហើយ ចឹងខ្ញុំច្រើនតែសេបគប់ជាមួយមិត្តភក្តិរបស់ខ្ញុំលេងលោតកៅស៊ូវិញ លេងជាមួយមិត្តភក្តិអីផ្សេង។

កៈ អូនឹងកាលពីបងនៅតូចៗណាបង?

ខៈ ចាជំនាន់វារៀងស្ទើរប្រហែលជាខ្ទង់១០ឆ្នាំហើយ។

កៈ អូបាទបង ចុះបងគិតថាបងធ្លាប់ធ្វើអីគេជាមួយបងប្អូនរបស់បងដែរ បងចូលចិត្តធ្វើហាស?

ខ៖ ភាគច្រើនពេលដែរជួបជុំគ្នាពេលយប់ ខ្ញុំច្រើនតែជួយមើលពួកគាត់រៀន ពេលដែរគាត់យកសៀវភៅមកអានអីចឹងទៅពេលកន្លែងណាដែរគាត់មិនចេះអីចឹងទៅ គាត់សួរខ្ញុំនឹងខ្ញុំនឹងប្រាប់គាត់។

ក៖ អូបងលក្ខណះថាបង្រៀនគាត់ពេលដែរយប់ណបង?

ខ៖ ចាជួយបង្រៀន។

ក៖ ចុះបងគិតថាបងធ្លាប់ទៅស្រែទៅធ្វើការងារអីជាមួយគាត់ទេ?

ខ៖ ការងារស្រែអីខ្ញុំមិនដែរធ្វើទេ។

ក៖ ចំការអីក៏មិនដែរធ្វើដែរណបង?

ខ៖ អត់ដែរធ្វើទេ និយាយរួមខ្ញុំនៅទីក្រុងរហូតនឹង។

ក៖ និយាយរួមបងជាអ្នកលក់ដូរដែរណបង?

ខ៖ និយាយខ្ញុំជាមនុស្សម្នាក់ដូចថាជាអ្នកប៉ាម៉ាក់កាត់មិនសូវអោយធ្វើអិទេ។

ក៖ បាទបងចុះបងប្អូនរបស់បងគាត់សព្វថ្ងៃគាត់រស់នៅណាដែរបង?

ខ៖ គាត់រស់ជុំគ្នា។

ក៖ ទាំងបងធំរហូតដល់ពៅនៅទីនោះដែរណបង?

ខ៖ ចានៅជុំគ្នានឹង។

ក៖ អត់តែបងនៅភ្នំពេញមួយទេ?

ខ៖ ជួបជុំគ្នទាំងអស់នៅភ្នំពេញទាំងម៉ាក់ ទាំងប៉ា។

ក៖ អូចឹងមានន័យថាឥឡូវនឹងពួកគាត់នៅភ្នំពេញទាំងអស់គ្នាហោសបង?

ខ៖ ចានៅភ្នំពេញនឹង។

ក៖ អូចុំបងប្អូនរបស់បងគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរបង?

ខ៖ ប្អូនទីប៉ុន្មានដែរ?

ក៖ ទាំងបងទាំងប្អូនហាសបង?

ខ៖ អូបងស្រីរបស់ខ្ញុំឥឡូវនេះគាត់ចាស់ហើយគាត់មិនសូវជាធ្វើការងារអីទេ គាត់ធ្វើការងារផ្ទះ និយាយរួមទៅ ។

ក៖ ចុះក្រុមគ្រួសាររបស់គាត់ធ្វើអីទៅបង?

ខ៖ គាត់ជាស្ត្រីមេម៉ាយ គាត់មានកូនមួយអាយុ២០ឆ្នាំជាងហើយជាកូនប្រុស កូនប្រុសនឹងធ្វើការ ហើយគាត់រស់នៅក្នុងបន្ទុកគ្រួសារលក្ខណះថាជាបងប្អូនទាំងអស់គ្នានឹងអែង។

ក៖ ចុះប្អូនទី៣វិញបង?

ខ៖ បន្ទាប់ខ្ញុំគាត់មានកូននៅក្បែរគា្ន គាត់ជួលផ្ទះនៅក្បែរគា្នគាត់រត់ tuk tuk។

ក៖ ចុះប្អូនទី៤វិញបង?

ខ៖ អាទី៤គាត់ធ្វើម្ហូបក្នុងហាងខាងចុងភៅ។

ក៖ ប៉ុន្តែនៅក្នុងទីក្រុងភ្នំពេញនឹង?

ខ៖ នៅទីក្រុងភ្នំពេញនឹងទេ តែនៅជាមួយខ្ញុំដែរ។

ក៖ អូបាទចុះទី៥វិញបង?

ខ៖ ទី៥ធ្វើការងារជាមួយជនជាតិគេ ជាលក្ខណះថាជាអ្នកបោសសំអាតផង ជាអ្នកមើលផ្ទះផងនឹងលក្ខណហាថាធ្វើជាការងារផ្ទះអោយជនជាតិគេចឹង។

ក៖ ចុះទី៦គាត់ធ្វើអីគេដែរបង?

ខ៖ ទី៦នឹងក៏គាត់ធ្វើការដែរ។

ក៖ ប៉ុន្តែដូចជាបងប្អូនរបស់បងដូចជាមានក្រុមគ្រួសារប៉ុន្មាននាក់ហើយបង?

ខ៖ ទាំងអស់៦នាក់។

កៈ ប៉ុន្តែដូចជាមានគ្រួសាររើរៀបការប៉ុន្មាននាក់ហើយបង?

ខៈ មានគ្រួសារ២នាក់ហើយ។

កៈ អូរៀបការបាន២នាក់ហើយនបង ចុះម្ដាយតរបស់បងគាត់មានឈ្មោះអីគេដែរបង?

ខៈ ម៉ាក់របស់ខ្ញុំពីមុននឹងគេហៅថាច្រេក ដល់ពេលដែរមកនៅភ្នំពេញ នឹងគេហៅថាហ៊ួ លាង
អេង។

កៈ គាត់ឈ្មោះហ៊ួ លាងអេងណបង ចុះម្ដាយរបស់បងគាត់អាយុប៉ុន្មានដែរបង?

ខៈ ម៉ាក់របស់ខ្ញុំគាត់អាយុ៦៦ឆ្នាំ។

កៈ ចុះគាត់កើតនៅថ្ងៃខែឆ្នាំណាបងមានចងចាំទេ?

ខៈ ខ្ញុំមិនអាចចាំបានទេ។

កៈ ចុះឆ្នាំខ្មែរគាត់ឆ្នាំអីគេដែរបង ដូចជាឆ្នាំជូត ឆ្លូវ ខាល ថោះហាសបងគាត់ឆ្នាំអីគេដែរបង?

ខៈ ខ្ញុំមិនសូវពិតប្រាកដទេប៉ុន្តែ ពីព្រោះអីខ្ញុំសួរគាត់តែគាត់មិនដែរប្រាប់ខ្ញុំច្បាស់ទេ ជួនកាល
គាត់ថាឆ្នាំសេះ ជួនកាលគាត់ថាឆ្នាំពពែ ពីរនឹងមិនដឹងជាមួយណាខ្ញុំចាំអត់បានច្បាស់ទេ។

កៈ បាទបងចុះគាត់រស់នៅណាបងមានចងចាំទេ?

ខៈ សព្វថ្ងៃនេះហោស?

កៈ អត់ទេដូចជាគាត់កើតនៅណាចឹងហាសម្ដាយរបស់បងហាស?

ខៈ ខ្ញុំលឺតែគាត់និយាយថាគាត់នៅស្ទូងកំពង់ធំ។

កៈ អូបាទម្ដាយរបស់បងអាយុប៉ុន្មានមិញដូចជាអាយុ៦៣ឆ្នាំ?

ខៈ គាត់អាយុ៦៦ឆ្នាំ។

កៈ អូគាត់អាយុ៦៦ឆ្នាំណបង ចឹងគាត់កើតនៅឆ្នាំ១៩៥២បង?

ខៈ ចាខ្ញុំមិនសូវចាំទេ។

កៈ ចុះឪពុករបស់បងគាត់មានឈ្មោះអីគេដែរបង?

ខៈ ប៉ារបស់ខ្ញុំនឹងសព្វថ្ងៃគេហៅថាតាតឿ តែគឡាត់នៅក្នុងសៀវភៅនឹងគាត់មានឈ្មោះថា ប្រាក់ ប៊ុនហ្វទេ។

កៈ អូបាទបង ចុះគាត់អាយុប៉ុន្មានដែរបង?

ខៈ គាត់អាយុ៧៥ឆ្នាំ ។

កៈ គាត់អាយុ៧៥ឆ្នាំ ចុះគាត់កើតនៅឆ្នាំណាបងមានចងចាំទេបង?

ខៈ ខ្ញុំអត់ចាំគាត់ទេ។

កៈ អូចុះគាត់កើតនៅណាបងមានដឹងទេ?

ខៈ លឺតែគាត់ថានៅស្គន់កំពង់ចាម។

កៈ អូគាត់នៅស្គន់កំពង់ចាមហោសបង ចុះគាត់អាយុ៧៥ឆ្នាំណបង ចឹងគាត់កើតនៅឆ្នាំ ១៩៤៣ហាសបង?

ខៈ ចានឹងហើយ។

កៈ ចុះគាត់កើតឆ្នាំខ្មែរហាសបងដូចជាឆ្នាំ ជូត ឆ្លូវ ខាល ថោះគាត់ឆ្នាំអីគេដែរបង?

ខៈ គាត់ឆ្នាំជូត។

កៈ ឆ្នាំជូតណបង ចុះឪពុករបស់បងគាត់ធ្វើអីគេសំរាបចិញ្ចឹមជីវិតដែរបង?

ខៈ ពីមុនគាត់ជាជាងប៉ះកង់ តែឥឡូវនឹងគាត់មិនធ្វើអីទេពីព្រោះគាត់ជាជនចាស់ជរាហើយ

កៈ អូគាត់ចាស់ហើយណបង?

ខៈ គាត់ចាស់ជរា។

កៈ ប៉ុន្តែគាត់ជាមនុស្សស្លូតរឺមួយក៏កាចដែរបង?

ខៈ បើតាមអ្វីដែរខ្ញុំរស់នៅជាមួយគាត់នឹងគាត់ជាមនុស្សដែរមឹងម៉ាត់។

កៈ ចឹងមានន័យថាគាត់ជាមនុស្សមិនស្លូត នឹងមិនកាច?

ខៈ ចានឹងហើយគាត់មឹងម៉ាត់។

កៈ ចុះម្ដាយរបស់បងគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរបង?

ខៈ ឥឡូវនឹងហោស។

កៈ អត់ទេតាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខៈ គាត់ជាអ្នកជំនួញ។

កៈ អុគាត់ជាអ្នកជួញដូរណាមីង?

ខៈ ចាគាត់ជាអ្នកជំនួញនឹង។

កៈ គាត់ទិញលក់ណាបង គាត់ជាអ្នកឈ្មួញកណ្ដាលណាបង?

ខៈ និយាយរួមទៅគាត់ជាអ្នកកគក់ដេដីផង ម៉ាជំនាន់គាត់នឹងគាត់លក់ស្អីក៏ខ្ញុំមិនដឹងដែរដឹងថាគាត់លក់ពេជ្រ។

កៈ អូចុះម្ដាយរបស់បងគាត់ស្លូត រឺមួយក៏កាចដែរបង?

ខៈ ម៉ាក់របស់ខ្ញុំស្លូតនឹង។

កៈ ចុះបងមានចងចាំអីរឺក៏អានុស្សាវរីយ៍អីកាលបីបងនៅជាមួយឪពុកម្ដាយរបស់បងហាស កាលដែរបងនៅជាមួយគាត់ហាសរហូតមកដល់ឥឡូវនឹងហាស ធ្លាប់ធ្វើអីគេខ្លះជាមួយគាត់ទេបង?

ខៈ ខ្ញុំតាំងពីដឹងក្ដីមកគ្រាន់ថាឪពុកម្ដាយរបស់ខ្ញុំនឹង ម៉ែរបស់ខ្ញុំមិនសូវមើលខ្ញុំទេ ប៉ុន្តែពីព្រោះគាត់ជាអ្នករកស៊ីជំនួញចឹងគាត់ទៅរកស៊ីបាត់ៗ។

កៈ អូគាត់ជាអ្នកជំនួញហោសបង?

ខៈ ភាគច្រើនខ្ញុំនៅជាមួយឪពុកចឹងឪពុកមើលកូនៗច្រើនជាងម្ដាយ។

ក៖ ចុះបងមានគិតថាមានធ្លាប់ធ្វើអីជាមួយឪពុកម្ដាយរបស់បងកាលនៅជាមួយឪពុកម្ដាយរបស់បងដែរគិតថាចាំអត់ភ្លេចហាសបង?

ខ៖ ដូចជាមិនមានបញ្ហាអីទេ ពីព្រោះអីនឹងធម្មតានៅក្នុងរង្វង់គ្រួសារតែងតែមានការខឹងខុសបន្តិចបន្តួចហើយមិនមានអីធ្ងន់ធ្ងរទេ។

ក៖ ចុះម្ដាយរបស់បងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិការពីគាត់នៅក្មេងទៅបងទេ?

ខ៖ ចំពោះម៉ាក់របស់ខ្ញុំដូចជាគាត់មិនសូវជានិយាយប្រវត្តិរបស់គាត់ទេពីព្រោះអីគាត់មិនសូវនៅផ្ទះទេ គាត់មិនសូវនៅផ្ទះទេ។

ក៖ ចុះឪពុករបស់បងគាត់មានធ្លាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទេបង?

ខ៖ គាត់និយាយរួមទៅគាត់មិនសូវទំនាក់ទំនងនិយាយពីពួកគាត់នៅក្មេងទេ ភាគច្រើនគ្រាន់តែគាត់និយាយថាកាលពីជំនាន់ស្រួលរកស៊ី ដល់ពេលដែរពេលបច្ចុប្បន្ននឹងពិបាករកស៊ីណាស់ ពីព្រោះថាមិនដឹងជាមូលហេតុអីទេ។

ក៖ ចុះដូចជាម្ដាយរបស់បងនឹងបងមានស្គាល់យាយតាខាងម្ដាយទេដូចជាគាត់មានឈ្មោះអីគេដែរបង?

ខ៖ អូយាយខាងប៉ាឈ្មោះយាយខ្ញុំភ្លេចបាត់ហើយនេះវាយូរហើយនឹង។

ក៖ អត់អីទេបង។

ខ៖ ដល់យាយខាងម៉ាក់ឈ្មោះយាយហាក់។

ក៖ ចុះតាវិញបង?

ខ៖ តាគាត់មានច្រើន។

ក៖ ចុះតាខាងម្ដាយគាត់មានឈ្មោះអីគេ?

ខ៖ តាខាងម្ដាយគាត់មានច្រើន។

ក៖ អូតាមានច្រើនហោសបង?

ខ៖ មិនដឹងជាតាឈ្មោះអីទេខ្ញុំមិនចាំទេ។

ក៖ ចុះតាខាងឪពុកវិញបងមានចងចាំទេ?

ខ៖ គាត់មានឈ្មោះ ប្រាក់។

ក៖ អូឈ្មោះ ប្រាក់ហោសបង ?

ខ៖ គាត់ឈ្មោះ សាយ ប្រាក់។

ក៖ ចុះយាយតាខាងម្ដាយគាត់កើតនៅឆ្នាំណាបងមានចងចាំទេ?

ខ៖ អូកើតអត់ទាន់តែម្ដងនឹង។

ក៖ យូរហើយណាបង?

ខ៖ ពីព្រោះអីម៉ាក់ប៉ារបស់ខ្ញុំការនឹងគាត់ស្លាប់បាត់ទៅហើយនឹង ដល់ពេលដែរជំនាន់ដល់ខ្ញុំទៀតមិនទៅដល់ណាបាត់ទៅ។

ក៖ ចុះយាយតាគាត់កើតនៅណាបងមានដឹងទេ?

ខ៖ យាយតាខាងម៉ាក់?

ក៖ យាយតាទាំងខាងម្ដាយនឹងទាំងខាងឪពុកហាស?

ខ៖ គាត់កើតនៅស្គន់កំពង់ចាម។

ក៖ នឹងខាងឪពុក?

ខ៖ ខាងឪពុកនឹង បើខាងម៉ាក់វិញនៅ ស្ទូងកំពង់ធំ សៀមរាប។

ក៖ ចុះដូចជាឪពុកម្ដាយរបស់បងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិឪពុកម្ដាយទៅបងទេ?

ខ៖ គ្រាន់តែប្រាប់ថាជីតារបស់ខ្ញុំគាត់ខ្សែចិន។

ក៖ នឹងខាងម្ដាយ?

ខ៖ ខាងប៉ាជីតារបស់ខ្ញុំខាងខ្សែចិន ហើយគាត់កាចណាស់ពីព្រោះអីប្រពៃណីចិនដឹងស្រាប់ហើយនឹង។

ក៖ រាងកាចណាបង?

ខ៖ ចាកាចច្បាប់ចិនគឺកាចណាស់។

ក៖ រាងតឹងណាបង?

ខ៖ សូម្បីតែយើងស្គាល់គ្នាល្មមៗនឹងក៏មិនសូវអោយយើងមានទំនាក់ទំនងគ្នាផងនឹងចាកាចណាស់។

ក៖ បាទបង ចុះមករស់នៅទីក្រុងភ្នំពេញនឹងយូរនៅបង?

ខ៖ ខ្ញុំរស់នៅយូរហើយតាំងពីប៉ៃតជាងមក និយាយរួមទៅខ្ញុំលឺម៉ាក់របស់ខ្ញុំប្រាប់មកថាតាំងពីបៃកពលពតនឹងមកខ្ញុំនៅភ្នំពេញនឹងរហូតនឹង។

ក៖ អូចឹងមានន័យថាប្រហែលជាចង់៤០ឆ្នាំហើយណាបង ប្រហែលជា៣៧-៣៨ឆ្នាំហើយណាបង?

ខ៖ ចានឹងហើយអស់៣៨ឆ្នាំ។

ក៖ បាទបង ចុះបងមានបងប្អូនណាដែររស់នៅក្រៅប្រទេសទេបង?

ខ៖ អត់មានទេ

ក៖ សាច់ញ្ញាតិអីក៏អត់មានដែរ?

ខ៖ បើសាច់ឆ្ងាយមាន

ក៖ នៅណាដែរបង?

ខ៖ មិនដឹងថានៅប្រទេសណាទេពីព្រោះអីនឹងម៉ាក់របស់ខ្ញុំមិនសូវបានទំនាក់ទំនងជាមួយដែរនឹង សាច់ឆ្ងាយតែមិនដឹងថានៅណា

ក៖ ប៉ុន្តែបងនៅលីវមិនទាន់មានគ្រួសារទេ?

ខ៖ នៅទេ

ក៖ អូបាទ ចុះបងចេះខ្មែរទេបង បងមានធ្លាប់បានរៀនទេ រឺក៏បងចេះអានអក្សរខ្មែរបានល្អប៉ុណ្ណាដែរបង?

ខ៖ អក្សរខ្មែរមធ្យមដែរមិនណាស់ណាទេ

ក៖ បងរៀនបានថ្នាក់ទីប៉ុន្មានដែរបង?

ខ៖ ខ្ញុំរៀនបានថ្នាក់ទី៨ចាស់

ក៖ អូថ្នាក់ទី៨នឹង?

ខ៖ ថ្នាក់ទី៨នៅជំនាន់ឆ្នាំ១៩៩៣

ក៖ ជំនាន់១៩៩៣ធម្មតាថ្នាក់ទី៨ទី៩នៅអនុវិទ្យាល័យណាបង?

ខ៖ នៅអនុវិទ្យាល័យនឹង

ក៖ ចុះកាលពីបងរៀននៅបឋមសិក្សានឹងសាលារបស់បងនៅណាដែរបង?

ខ៖ វិទ្យាល័យវត្តកោះ

ក៖ រៀននៅវត្តកោះណាបង ចុះអនុវិទ្យាល័យបងរៀននៅណាដែរបង?

ខ៖ វិទ្យាល័យវត្តកោះ ដល់ពេលបឋមសិក្សានឹងនៅបឋមសិក្សាបដិវត្តន៍នៅជិតផ្សារតាប៉ាង

ក៖ ចុះបងធ្លាប់មានមិត្តភក្តិណាដែរធំធាត់មកជាមួយគ្នាទេបង?

ខ៖ ពួកខ្ញុំតាំងពីបែកគ្នាមក បែករហូតអត់មានការជួបគ្នាទេ

ក៖ បងកាលនៅក្មេង រឺក៏បងកាលពីនៅរៀនមានមិត្តភក្តិស្និទ្ធិស្នាលទេ?

ខ៖ មានច្រើនដែរ

ក៖ ប៉ុន្តែបងអាចរៀបរាបឈ្មោះខ្លះៗបានទេបង?

ខ៖ អូអត់ចាំទេយូរហើយជាង២០ឆ្នាំហើយនឹង

ក៖ អូសូម្បីតែឈ្មោះម្នាក់ក៏បងអត់ចាំដែរណាបង?

ខ៖ ចាពីព្រោះអីតាំងពីប្រលងមកបែកគ្នារហូតមិនដឹងថាគាត់ទៅទីណាហើយក៏មិនដឹងថាម៉េចទេភ្លេចអស់ហើយ ប៉ុន្តែបើឃើញមុខប្រហាក់ប្រហែលដែរនឹង

ក៖ ប្រហាក់ប្រហែលណាបង ចុះបងមានចងចាំរឺក៏អនុស្សាវរីយ៍អីជាមួយគ្នាទេកាលពីនៅរៀនជាមួយមិត្តភក្តិរបស់បងហាស?

ខ៖ មានពួកខ្ញុំពេលដែរម៉ោងលីបអីច្រើនតែនៅអង្គុយនៅជួបជុំគ្នានៅមុខសាលារៀន ទិញមកចែកគ្នាញ៉ាំចឹងទៅ

ក៖ ចុះធ្លាប់មានអនុស្សាវរីយ៍អីថា ឧទាហរណ៍ធ្លាប់ទៅសាលាអីមានការបណ្តើរម៉ូតូរឺក៏បណ្តើរកងអីជាមួយគ្នាអីចឹងហាសបង?

ខ៖ អត់ទេជំនាន់ខ្ញុំនឹងពួកម៉ាក់ប្រុសច្រើនយតែគេមកហៅខ្ញុំមកដល់ផ្ទះចឹងទៅក៏ទៅជាមួយគ្នាចឹងទៅ អ្នកខ្លះគេមានកងចឹងទៅក៏គេមកឌុបខ្ញុំទៅ

ក៖ អត់ធ្លាប់មានពិន័យអីពីគ្រូអីទេណាបង?

ខ៖ ចាអត់មានទេបង អត់មានវិន័យអីទេ

ក៖ ចុះបងស្រីធ្លាប់ទៅការនៅវាលស្រែអីទេបង លក្ខណៈធ្វើស្រែចំការហាស?

ខ៖ ខ្ញុំធ្លាប់ទៅស្រែទៅមើលគេដែរពេលខ្លះក៏ចង់ធ្វើដែរ ប៉ុន្តែគេថាមិនចាប់ធ្វើទេនាំតែប្រលាក់ខោអាវអីចឹងហាសណាហើយមានការពិបាកនៅពេលដែរយើងអត់ចេះចឹងមានការពិបាកនៅក្នុងការគេជួយប្រាប់យើងអីចឹងហាស ក៏ខ្ញុំអត់ធ្វើទៅ

ក៖ ចុះបងមានធ្លាប់ធ្វើអាជីវកម្មអីនៅក្នុងគ្រួសារទេបង?

ខ៖ សព្វថ្ងៃនេះខ្ញុំធ្វើជាអ្នកសំអាតនៅផ្ទះគេ ហើយសល់ម៉ោងក៏ខ្ញុំរកស៊ីថ្លឹងជញ្ជីងទៅ

ក៖ ប៉ុន្តែបងមានធ្លាប់ចិញ្ចឹមមាន់ ទា ជ្រូក គោអីទេបង កាលពីមុនហាស?

ខ៖ កាលពីមុនអត់មានចិញ្ចឹមទេមានតែឆ្កែ ឆ្មា

ក៖ អូមានតែឆ្កែ នឹងឆ្មាណាបង?

ខ៖ បើឆ្កែនឹងឆ្មាមាន

ក៖ បាទបងចុះបងគិតថាធ្លាប់ធ្វើអីគេខ្លះតាំងពីក្មេងរហូតមកដល់ពេលនេះហាសបង ការងារពេលក្មេងបងធ្វើអីគេខ្លះ ហើយដល់ពេលឥឡូវនឹងបងធ្វើអីគេខ្លះដែរចឹងហាសបង?

ខ៖ កាលពីក្មេងខ្ញុំមិនសូវដែរធ្វើអីទេ ប៉ុន្តែខ្ញុំធ្លាប់សាកល្បងលក់នុំអីទៅដល់ពេលដែរវាមិនសូវដាច់ចឹងទៅក៏វាផ្អាកលក់អីចឹងទៅណា ហើយដល់ពេលណុងទៅក៏ខ្ញុំទៅរៀនកាត់ដេរ ពេលដែរខ្ញុំទៅរៀនកាត់ដេរនឹងគោលបំណងនឹងចង់ក្លាយជាជាងកាត់ដេរ ហើយដោយសារតែសុខភាពរបស់ខ្ញុំវាខ្សោយពេក ក៏ខ្ញុំបោះបង់ការរៀនកាត់ដេរនឹងចោលទៅ

ក៖ រហូតមកដល់ឥឡូវនឹងបងចាប់ផ្តើមធ្វើការ?

ខ៖ ដល់ពេលឥឡូវនឹងក៏ខ្ញុំចាប់ផ្តើមជួយធ្វើការតាមផ្ទះគេហើយ ក៏បានដើរថ្លឹងចឹងទៅក៏វាមានសុខភាពល្អទៅ

ក៖ ចុះពីមុននឹងបងធ្វើការងារមួយនឹងបងមានធ្លាប់ធ្វើអីផ្សេងទៀតអត់បង?

ខ៖ ដូចជាអត់ដែរទេ ខ្ញុំទៅរៀនដេរដែរតែខ្ញុំរៀនមួយវគ្គចឹងទៅខ្ញុំឈប់ ខ្ញុំមកថ្លឹងវិញនឹង ខ្ញុំធ្លាប់ច្រើនតែការងារនឹងខ្ញុំទៅដេរនៅរោងចក្រ អូមិនមែនរោងចក្រទេរបៀបឯកជនចឹងហាស ខ្ញុំធ្វើដូចជាអ្នកមើលការខុសត្រូវគេនៅទីនោះនឹង

ក៖ ប៉ុន្តែបងថាថ្លឹងនឹងបងថ្លឹងអីគេវិញបង?

ខ៖ ថ្លឹងជញ្ជីងថ្លឹងគីឡូនឹង

ក៖ ជញ្ជីងថ្លឹងគីឡូអានឹងគេថ្លឹងអីគេអានឹងហោសបង?

ខ៖ អានឹងគេដើរថ្លឹងមនុស្ស

ក៖ អូលក្ខណៈថាយើងកាន់ជញ្ជីងអោយគេថ្លឹងនឹងមែនបង?

ខ៖ យើងដើរចឹងទៅគេថ្លឹងទៅគេក៏អោយប្រាក់យើងមកនឹងហាស

ក៖ អូបាទបងចុះបងគិតថាជីវិតរបស់បងតាំងពីក្មេងរហូតមកដល់ពេលនេះមានការផ្លាស់ប្តូរអីគេខ្លះដែរបង ពីក្មេងនឹងបងយ៉ាងម៉េចដែរដល់ពេលឥឡូវនឹងបងគិតថាបងមានការផ្លាស់ប្តូរអីគេដែរចឹងហាស?

ខ៖ គ្រាន់តែថាពីក្មេងយើងរស់នៅជាមួយឪពុកម្តាយយើងមិនសូវខ្វល់ខ្វាយ ព្រោះបងមានឪពុកម្តាយជាអ្នកផ្តល់អោយ ជាអ្នកមើលថៃយើង ដល់ពេលយើងរាងធំពេញវ័យហើយនឹងក៏យើងនៅតែស្ថិតនៅក្នុងការគ្រប់គ្រងរបស់គាត់ដែរនឹងចឹងម៉ាក់ប៉ារបស់ខ្ញុំមិនសូវបណ្តោយអោយខ្ញុំទៅធ្វើការរឺក៏រកស៊ីអីទេពីព្រោះអីខ្ញុំដូចថាជាមនុស្សដែរទន់ខ្សោយចឹងហាសមិនសូវមានសុខភាពល្អអីចឹងហាស ច្រើនតែគាត់មើល ហើយនឹងផ្តល់អាហារអោយនៅជាមួយគាត់ប៉ុន្តែរយះពេលក្រោយប្រហែលជា១៥-២០ឆ្នាំនេះខ្ញុំក៏ដើរអារឿងថ្លឹងនឹងទៅក៏មានជីវភាពសមផ្លាស់ប្តូរៗទៅថ្ងៃណាទៅបានច្រើនៗថ្ងៃណាបានតិចៗ ហើយមួយរយះក្រោយនឹងក៏ខ្ញុំអរគុណព្រះជាម្ចាស់ ដែរព្រះអង្គបានរៀបចំផ្លូវអោយសំរាប់ខ្ញុំនឹងល្អជាងមុនឆ្ងាយដែរ

ក៖ អូបាទល្អបង

ខ៖ ទោះបីបានតិចប៉ុន្តែព្រះអង្គរៀបចំផ្លូវអោយខ្ញុំបានស្រួលដែរក្នុងការរកប្រាក់

ក៖ ចុះបងគិតម្ហូបអីគេដែរតាំងពីក្មេងរហូតមកដល់ពេលនេះហាសដែរបងគិតថាចូលចិត្តពិសារជាងគេដែរបង?

ខ៖ និយាយទៅរឿងមុខម្ហូបនឹងមានការផ្លាស់ប្តូររហូតនឹង មិនអាចថាពីក្មេងខ្ញុំចូលចិត្តអានេះហើយឥឡូវនឹងខ្ញុំនៅតែចូលចិត្តដដែលអត់មានទេផ្លាស់ពីព្រោះផ្លាស់ទាំងរស់ជាតិផ្លាស់ទាំងមុខម្ហូបទៀតនឹង

ក៖ ប៉ុន្តែឥឡូវនឹងបងចូលចិត្តម្ហូបអីគេដែរបង?

ខ៖ ប៉ុន្មានឆ្នាំនេះខ្ញុំចូលចិត្តតែបន្លែទេ ហើយនឹងសាច់អីខ្ញុំមិនសូវញាំុទេ

ក៖ ប៉ុន្តែបងគិតថាមានស្ងោរ ម្ជូរ ចៀន ឆាអីគេដែរបងចូលចិត្តដែរភាគច្រើនហាស?

ខ៖ ភាគច្រើនចូលចិត្តជាងគេមានតែត្រីអាំង នឹងស្លម្ជូរ

កៈ ចុះការី កក្ងរអី រីសេម្លប្រហើរអីបងមិនសូវចូលចិត្តទេ?

ខៈ ម្តងម្កាលបានអានឹងហោស

កៈ ចុះបងគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះហាស គិតថាល្បែងប្រជាប្រិយ៍អីដែរបង គិតថាចូលចិត្តលេងហាសបង?

ខៈ ពីក្មេងខ្ញុំនិយាយទៅវាមានរដូវកាលពេលខ្លះគេលេងមឹកក៏ទៅលេងមឹកនឹងគេ ពេលខ្លះគេទៅលេងគប់វង់ក៏ទៅលេងគប់វង់នឹងគេ គេលេងហាក់កំពស់ក៏ទៅលេងជាមួយនឹងគេ

កៈ ក៏ទៅហាក់កំពស់ចាមួយនឹងគេទៅ?

ខៈ ចាដល់ពេលដែរចូលឆ្នាំគេចាក់បាសរាំក៏ទៅមើលគេពីព្រោះអីខ្ញុំមិនចេះរាំទេ

កៈ ចុះលក្ខណៈថាល្បែងប្រជាប្រិយ៍ចោលឈូង លាក់កន្សែង ពង្រត់កូនក្រមុំ បោះអង្គុញអី បងចូលចិត្តទេបង?

ខៈ ខ្ញុំចូលរួមមើលបានពីព្រោះមានអារម្មណ៍ថាក្នុងការចូលរួមមើលនឹងលេងនឹងវាហាត់យ៉ាង ម៉េចខ្ញុំអត់សូវចេះ និយាយទៅភាគច្រើនអត់លេងទេប៉ុន្តែមើលបាន

កៈ អូប៉ុន្តែបងចូលចិត្តមើលគេលេងណាបង?

ខៈ ចូលចិត្តមើលគេលេងប៉ុន្តែខ្លួនឯងអត់លេងទេ

កៈ បាទដោយសារតែលេងវាហាត់ពេកណាបង?

ខៈ ចាហាត់ដែរនឹង

កៈ អូចុះបងគិតថាចំរៀងដែរបងគិតថាបានរៀនច្រៀងតាំងពីក្មេងរហូតមកដល់ពេលនេះ ហាស?

ខៈ ភាគច្រើននឹងខ្ញុំច្រៀងទៅវាមិនបានពេញមួយបទទេ ខ្ញុំចាំតែមួយកំណាត់ៗៗនឹង

កៈ អូបងចាំមួយកំណាត់ៗៗហោសបង ប៉ុន្តែបងអាចប្រាប់បានថាបទចំរៀងដែរបងចាំមួយ កំណាត់នឹងមានឈ្មោះអីគេចឹងហាស?

ខ៖ បាត់ដំបងបណ្ដូលចិត្ត

ក៖ បងអាចដាក់មួយឃ្លាបានទេ?

ខ៖ អត់ទេមិនអាចបានទេ

ក៖ អូបាទបងខ្ញុំនិយាយលេងទេបង ចុះភាគច្រើនបងចូលចិត្តស្ដាប់បទចំរៀងទេបង?

ខ៖ បទចំរៀងនឹងខ្ញុំចូកចិត្តស្ដាប់បទសិនស៊ីសាម៉ុត បទពីដើមខ្ញុំចូលចិត្ត

ក៖ តែបទសម័យបងមិនសូវចូលចិត្តទេ?

ខ៖ បទសម័យខ្ញុំមិនសូវជាពេញនិយមពេញចិត្តទេ

ក៖ អូចុះបងមានមិត្តភក្តិរឺបងប្អូននៅក្នុហាក្រុមគ្រួសារណាដែរចេះលេងឧបករណ៍ភ្លេងទេបង?

ខ៖ អត់មានទេ

ក៖ ចុះទាំងឧបករណ៍ភ្លេងខ្មែរនឹងឧបករណ៍ភ្លេងដូចជាព្យាណូ រឺហ្គីតាអីចឹងហាស?

ខ៖ អត់មានទេបងប្អូនរបស់ខ្ញុំគេមិនសូវជាចាប់អារម្មណ៍ខាងលេងភ្លេងចំរៀងទេ

ក៖ ប៉ុន្តែបើមិត្តភក្តិមាន?

ខ៖ បើមិត្តភក្តិមាន

ក៖ ភាគច្រើនពួកគាត់លេងអីគេដែរបង?

ខ៖ សព្វថ្ងៃនេះហោស សព្វថ្ងៃនេះនៅព្រះវិហារមានច្រើនណាស់

ក៖ ប៉ុន្តែពួកគាត់ចូលចិត្តលេងអីគេដែរបង?

ខ៖ ភាគច្រើនពួកគាត់ច្រៀង គាត់ត្រូវលេងហ្គីតា ហើយគាត់ត្រូវលេងគោះអាស្គរទូងៗនឹងមាន គាត់មានការផ្លាស់ប្ដូរគ្នាគ្រប់គ្នានឹងពួកគាត់

ក៖ ចុះបងគិតថាផ្ទះរបស់បងមានលក្ខណះបែបណាដែរបងតាំងពីក្មេងរហូតមកដល់ពេលនេះ ហាសបង?

ខ៖ អូផ្ទះរបស់ខ្ញុំមានការផ្លាស់ប្តូរគ្រប់ទីកន្លែងពីព្រោះអីម៉ាក់របស់ខ្ញុំគាត់មានជំងឺច្រើន ដល់ពេលចឹងត្រូវផ្លាស់ពីកន្លែងមួយទៅកន្លែងមួយចឹងហាស

ក៖ អូកាលពីក្មេងផ្ទះយ៉ាងម៉េចដែរបង?

ខ៖ កាលពីក្មេងដីរបស់ខ្ញុំធំចឹងផ្ទះរបស់ខ្ញុំមិនសូវជាស្អាតប៉ុន្មានដែរទេ ផ្ទះយើងមិនសូវស្អាតទេ ប៉ុន្តែបានដីធំទូលាយធំហើយវែង

ក៖ ផ្ទះថ្មរឺក៏ផ្ទះឈើដែរបង?

ខ៖ ផ្ទះឈើទេ

ក៖ អូឈើទាំងលើទាំងក្រោមណាបង?

ខ៖ ចាផ្ទះឈើនឹង ប៉ុន្តែម៉ាក់របស់ខ្ញុំគាត់មានដីធំនឹង

ក៖ ចុះកាលផ្ទះរបស់បងកាលពីក្មេងនឹងនរណាគេជាអ្នកសាងសងដែរបង ដូចជាជួលគេធ្វើ រឺក៏ធ្វើដោយខ្លួនឯងហោសបង?

ខ៖ អូម៉ាក់ប៉ារបស់ខ្ញុំគាត់ទិញគេ

ក៖ អូទិញតែម្តងហោសបង ចុះម៉ាក់ប៉ារបស់បងគាត់ចេះធ្វើផ្ទះទេ?

ខ៖ បើសិនជាជួសជួលបន្តិចបន្តួចគាត់អាចធ្វើបាន ប៉ុន្តែបើថាជាគំរោងតែម្តងគាត់ធ្វើអត់បានទេ

ក៖ អូលក្ខណះថាជួសជួលជាបន្ទប់អីនឹងហោសបង?

ខ៖ ចាអានឹងគាត់អាចធ្វើបាន

ក៖ អូគាត់ចេះមកពីនរណាគេដែរបង?

ខ៖ ខ្ញុំអត់ដឹងដែរនឹង អត់ដែរសើបសួរគាត់ផងនឹង

ក៖ ប៉ុន្តែបងមានដឹងថាយាយតាទាំងខាងម្តាយ នឹងទាំងខាងឪពុកគាត់ចេះធ្វើទេចេះធ្វើផ្ទះហាសឪពុកម្តាយរបស់បងគាត់មានធ្លាប់ប្រាប់ទេ?

ខ៖ ដូចជាអត់សូវដឹងដែរនឹង

ក៖ អូបាទអត់អីទេបង ចុះបងមានដឹងថាគេប្រើឧបករណ៍អីគេខ្លះសំរាប់ប្រើប្រាស់សាងសងផ្ទះមួយណុងហាសបង?

ខ៖ អត់សូវដឹងទេ

ក៖ ចុះដូចជាបងគិតថាបងមានជំនាញអីគេដែរបងចេះស្ទាត់ជំនាញជាងគេដែរបង?

ខ៖ ស្ទាត់ជំនាញជាងគេនឹងមានតែការរៀបចំផ្ទះនឹង

ក៖ ចុះបងគិតថាឪពុកម្ដាយរបស់បងគាត់ធ្លាប់បង្រៀនពីជំនាញអីទៅដល់បងទេ?

ខ៖ អត់ដែរបង្រៀនទេគ្រាន់តែគាត់ប្រាប់ថា បើយើងចង់ធ្វើអីយើងទៅរៀនខាងនឹងទៅ

ក៖ ប៉ុន្តែដូចជាបង្រៀនធ្វើម្ហូបធ្វើអីនៅផ្ទះហាស គាត់មានដែរបានបង្រៀនទេបង?

ខ៖ គាត់អត់ដែរបង្រៀនទេ គ្រាន់តែការងារផ្ទះគាត់មិនសូវអោយយើងធ្វើទេនិយាយទៅកាលពីមុនមានអ្នកនៅជាមួយចឹងទៅគាត់អោយគេធ្វើហាស

ក៖ ចុះបងគិតថាពេលណាដែរបងគិតថាជាពេលដែរបងលំបាកនៅក្នុងជីវិតរបស់បងទេ?

ខ៖ មានដែរមិនមែនអត់ទេ ពេលខ្លះដែរយើងអត់ យើងរកមិនបានយើងថាយើងពិបាកក្នុងការធ្វើអត់ដឹងថាបានអីហូបនឹងមិនដឹងថាធ្វើអីកើត ចាមានមិនមែនថាអត់ទេ

ក៖ ប៉ុន្តែដូចជាក្មេងបងមានការពិបាកអីគេដែរបង បងមានការលំបាកអីអត់បង?

ខ៖ កាលនៅពីក្មេងអត់មានការពិបាកអីទេ ពេលណាដែរឃើញគ្រួសាររបស់យើងរកបានទៅក៏សប្បាយទៅ ប៉ុន្តែពេលណាដែរឃើញគាត់រកមិនសូវបានចឹងទៅក៏ពិបាកចិត្តជាមួយគាត់ដែរចឹងទៅណា

ក៖ ប៉ុន្តែកាលពីជំនាន់ពលពតបងនៅប៉ុណ្ណាទៅបង?

ខ៖ លឺប៉ាក់ខ្ញុំថាពេលដែរជំនាន់ពលពតខ្ញុំមានអាយុប្រហែលជា២ឆ្នាំហើយនឹង

ក៖ អូទើបតែ២ឆ្នាំទេណបង ប៉ុន្តែពេលណុងបងនៅជាមួយក្រុមគ្រួសារ?

ខ៖ នៅបងស្រីរបស់ខ្ញុំនឹងមើលខ្ញុំ

ក៖ បាទបងចុះរហូតមកដល់ពេលជំនាន់ខ្មែរក្រហមនឹងនៅលើៗទៀតនឹងបងធ្វើអីគេដែរទៅបង?

ខ៖ និយាយរួមនឹងខ្ញុំនៅតូចនឹង បើនិយាយទៅបើខ្ញុំចាំបាននឹង ខ្ញុំចាំតែជំនាន់១៩៨៣តែម្តងនឹងខ្ញុំបានទៅរៀនហើយនឹង

ក៖ អូបងទៅរៀនណាបង ចុះកាលពីជំនាន់ណុងបងនៅកំពង់ធំ រឺមួយក៏នៅភ្នំពេញហើយដែរបង?

ខ៖ ខ្ញុំនៅភ្នំពេញនឹងតា

ក. ប៉ុន្តែពេលណុងបងចាប់ផ្តើមចូលរៀនហើយមែនទេបង?

ខ៖ ចាខ្ញុំចូលរៀនហើយនឹង

ក៖ អូបាទចុះបងគិតថាបងឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរបង ដូចថាកាលលំបាកតាំងពីក្មេងរហូតមកដល់ឥឡូវនេះហាស ដូចឥឡូវអីនឹងពីមុនអីចឹងហាស បងឆ្លងកាត់វារបៀបណាទៅបង?

ខ៖ បើនិយាយពីរឿងជីវិតឆ្លងកាតនឹង វាមានលក្ខណៈថាវាមិនរហូតទេតែម្តងមួយកាលទេ

ក៖ ដោយផ្នែកៗចឹងហោសបង?

ខ៖ ចាដូចថាពេលខ្លះដែរយើងពិបាកចិត្តទៅ ពេលដែរឃើញឪពុកម្តាយរបស់យើងអត់លុយចឹងទៅយើងក៏ពិបាកចិត្តចឹងទៅ យើងត្រូវធ្វើអីដើម្បីអោយមានលុយ យើងត្រូវរៀនផ្នែកណាទៅដើម្បីអោយយើងមានការងារធ្វើអីចឹងហាសណាស់

ក៖ បាទត្រូវហើយបង?

ខ៖ ថាបើអត់ពីពុកម្តាយរបស់យើងទៅ យើងត្រូវរៀនចំនេះណាដែរយើងអាចធ្វើការមួយដែរមានជីវភាពអោយបានល្អជាងឪពុកម្តាយរបស់យើងទៀតចឹងហាស

កៈ បាទបងចុះបងគិតថាពេលណាដែរបងគិតថាជាពេលដែរបងសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់បងដែរហាស?

ខៈ អរពេលដែរខ្ញុំសប្បាយជាងគេគឺលក្ខណៈមួយថាបងប្អូននៅក្នុងក្រុមគ្រួសាររបស់ខ្ញុំមិនមានការទាស់ទែងគ្នាទៅ នឹងពេលដែរកាត់បានជួបជុំគ្នាគាត់សប្បាយជាមួយគ្នាចឹងទៅ

កៈ ចឹងមានតែពេលដែរបងជួបជុំបងប្អូនគឺជាពេលដែរបងសប្បាយជាងគេហើយណបង?

ខៈ ចាសប្បាយដែរនឹងជួបជុំគ្នានឹងលក្ខណៈថាគាត់មិនមានការទាស់ទែងគ្នាអីចឹងទៅណាពេលដែរគាត់ជួបជុំគ្នាទៅក៏មានការលេងសើចជាមួយគ្នាអីចឹងទៅ

កៈ នឹងជាពេលដែរបងសប្បាយជាងគេ?

ខៈ ចានឹងសប្បាយនៅក្នុងក្រុមគ្រួសារ

កៈ ជុះតាំងពីក្មេងរហូតមកដល់ពេលនេះហាស បងគិតថាបងធ្លាប់មានក្តីសង្ឃឹម រឺក្តីស្រម៉ៃថាបងចង់ធ្វើអីគេដែរទេបង?

ខៈ ខ្ញុំមានគោលបំណងពីរថាពេលដែរខ្ញុំចំឡើងខ្ញុំចង់ធ្វើជាជាងដេរមួយនឹង មួយទៀតខ្ញុំចង់ធ្វើជាអ្នកលក់ចាប់ហួយ

កៈ អូប៉ុន្តែបងដូចជាមិនទាន់បានសំរេចនៅគោលបំណងរបស់បងទេ?

ខៈ ខ្ញុំអត់ទាន់បានសំរេចទេ គោលបំណងទាំងពីរនេះខ្ញុំចាប់អត់ទាន់បានទេឮ

កៈ ជាចុងក្រោយបើចង់អោយបងផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗរឺមួយក៏បងប្អូនកូនក្មួយរបស់បងហាស តើបងគិតថាបងចង់ផ្តែផ្តាំអីទៅពួកគាត់ដែរបង?

ខៈ អូជាចុងក្រោយខ្ញុំចង់ប្រាប់ថាមិនថានៅសម័យកាលណាក៏ត្រូវការចំនេះដឹងដែរ ដូចនេះបើយើងមានចំនេះដឹងយើងស្រួលនឹងរកការងារធ្វើ តែបើយើងអត់មានចំនេះដឹងទេនោះយើងនឹងពិបាករកការងារធ្វើណាស់ហើយពិបាកក្នុងការរកលុយកាក់ចំណូលច្រើននឹងបើកាលនឹង បើយើងមានចំនេះខ្ពស់យើងអាចរកប្រាក់ចំណូលវាបានច្រើនដែរ ហើយក៏មានមុខមាត់កេរ្តិ៍យសល្អដែរនឹង

កៈ ចុះបងមានគិតថាបងប្អូនកូនក្មួយរបស់បងថាចង់អោយពួកគាត់បានសំរេចគោលបំណង របស់បងដែរបងបានគិតហាសចង់អោយកូនក្មួយអីចង់សំរេចគោលបំណងរបស់បងទេ រឺយ៉ាង ម៉េចដែរបង?

ខៈ បើខ្ញុំវិញគោលបំណងរបស់របស់ខ្ញុំចំពោះខ្ញុំគឺវាបរាជ័យហើយនឹង អត់បានសំរេចប៉ុន្តែ គោលបំណងរបស់ខ្ញុំនឹងខ្ញុំចង់បានកូនក្មួយរបស់ខ្ញុំធ្វើការវិញ ខ្ញុំចង់អោយក្មួយៗរបស់ខ្ញុំខំរៀន ទៅ ហើយវាមានចំនេះដឹងខ្ពង់ខ្ពស់ វាងាយស្រួលនឹងរកការងារធ្វើ ធ្វើការទៅវាមានមុខមាន មាត់ហើយវាមិនសូវនឿហត់ប៉ុន្មានដែរទេនឹង

កៈ បងមានអីដែរចង់ផ្តែផ្តាំទៅពួកគាត់អីផ្សេងទៀតទេបង?

ខៈ អើរខ្ញុំចង់អោយថា……..

កៈ ដូចលក្ខណៈថាខ្ញុំចង់អោយគាត់ដើរនៅក្នុងសង្គមបានហើយ កុំអោយពួកគាត់មានការ ភ្លើតភ្លើនអីចឹងហាសបង?

ខៈ ចាខ្ញុំចង់ថាសូមអោយកុមារីមួយក៏យុវជនទាំងអស់នឹងកុំអោយប្រើគ្រឿងញៀនទី១ ទី២ នឹងសូមអោយពួកគាត់បានស្គាល់បីឪពុកម្តាយនឹងអោយពួកគាត់បានស្គាល់ព្រះអោយបាន ច្រើន អោយគេគោរពព្រះអង្គ អោយគេកោតខ្លាចព្រះអង្គ ស្គាល់ពីព្រះហរទ័យព្រះអង្គអោយ បានច្បាស់ ដើម្បីអោយគេបានសំរេចអនាគត់គេទៅថ្ងៃអនាគត

កៈ បាទបងចឹងមានអីផ្សេងទៀតទេបង?

ខៈ អត់មានទេ ហើយសូមអោយព្រះអង្គជាព្រះការពាររាល់ដំណើរមនុស្សទាំងអស់នឹង យុំ គ្រងការពារពួកគាត់កុំអោយមានរឿងអីហាស ហើយសូមអោយព្រះអង្គជាព្រះនឹងប្រទាន់ពរ សំរាប់ប្រទេសកម្ពុជាយើងនឹង

កៈ បាទបងចឹងជាចុងក្រោយប្អូនសូមអរគុណបងដែរបានចំណាយពេលដែរបានពិភាក្សា ជាមួយនឹងខ្ញុំហើយដូចជាចំណាយពេលដែរបានផ្តល់បទពិសោធន៍ហើយនឹងប្រវត្តិរបស់បង ដើម្បីទុកដំកុលទៅក្នុងវេបសាយរបស់សាលាហាស ហើយពេលដែរខ្ញុំសំភាសន៍បងហើយខ្ញុំ នឹងដំកុលប្រវត្តិមួយនឹងទៅក្នុងវេបសាយរបស់សាលាបង ចឹងជាចុងក្រោយខ្ញុំអរគុណបង ហើយ ខ្ញុំសូមជូនពរបងអោយមានសុខភាពល្អហើយនឹងមានសុភមង្គលនៅក្នុងក្រុមគ្រួសារនឹង រកស៊ីមានបានណាបង

ខ៖ ចាអរគុណដូចគ្នា

ក៖ បាទអរគុណច្រើនដែរណាបង៕